**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលជំនួបរវាង ឯកឧត្តម លុយ ដាវីត រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាមួយ លោកសាស្ត្រាចារ្យ វិទិត មុនតាប៊ន អ្នករាយការណ៍ពិសេសទទួលបន្ទុក ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង១៦:៣០នាទីរសៀល ឯកឧត្តម **លុយ ដាវីត រដ្ឋលេខាធិការ** និងជាតំណាងដ៏ខ្ពង់ខ្ពស់**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**បានទទួលជួបពិភាក្សាការងារតាមប្រព័ន្ធវីដេអូជាមួយលោកសាស្ត្រាចារ្យ **វិទិត មុនតាប៊ន** អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។

ឯកឧត្តមរដ្ឋលេខាធិការបានជម្រាបជូនអ្នករាយការណ៍ពិសេសអំពីការសម្រេចបានរបស់កម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ នៅក្នុងឆ្នាំ២០២១ និងជោគជ័យថ្មីៗ នៃកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន ដែលបានប្រព្រឹត្តទៅកាលពីខែកុម្ភៈ ឆ្នាំ២០២២។ អាទិភាពរបស់កម្ពុជាក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២ ក៏ត្រូវបានលើកឡើងនៅក្នុងឱកាសនៃជំនួបផងដែរ។

ការចូលរួមយ៉ាងសកម្មរបស់កម្ពុជានៅក្នុងវេទិកាពហុភាគីផ្សេងៗ គឺឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់កម្ពុជាឆ្ពោះទៅរកគោលការណ៍ពហុភាគី ក៏ដូចជាការឆ្លើយតបនឹងបញ្ហាប្រឈមជាយុទ្ធសាស្ត្រនៅក្នុងតំបន់នាពេលបច្ចុប្បន្ន ដែលត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈមូលបទនៃកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ «ការពង្រឹងពហុភាគីនិយម ដើម្បីកំណើនរួម» និង «អាស៊ានរួមគ្នាដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា» សម្រាប់ភាពជាប្រធានអាស៊ានរបស់កម្ពុជាក្នុងឆ្នាំ២០២២។

ពាក់ព័ន្ធនឹងលំហសង្គមស៊ីវិល សិទ្ធិនយោបាយ និងប្រជាធិបតេយ្យ ឯកឧត្តមរដ្ឋលេខាធិការបានគូសបញ្ជាក់ថា រាល់ការវាយតម្លៃចំពោះកម្ពុជាគួរផ្តោតការយកចិត្តទុកដាក់លើការវាយតម្លៃពីគ្រប់មជ្ឈដ្ឋានទាំងអស់។ ក្នុងនាមជាប្រទេសដែលធ្លាប់បានឆ្លងកាត់សង្គ្រាមស៊ីវិល កម្ពុជាបច្ចុប្បន្នបានក្លាយជាប្រទេសមួយដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅក្នុងពិភពលោក

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ដោយទទួលបានអត្រាកំណើនជាមធ្យម៧ភាគរយ នៅមុនវិបត្តិជំងឺកូវីដ-១៩។ សមិទ្ធផលទាំងអស់នេះពិតជាមិនអាចសម្រេចបានទេ ប្រសិនបើគ្មានសន្តិភាព និងស្ថិរភាពដែលជាបុរេលក្ខខណ្ឌដែលមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។

កម្ពុជាប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលបច្ចុប្បន្នមានគណបក្សនយោបាយចំនួន៤៧ ដោយក្នុងនោះមានគណបក្សនយោបាយចំនួន១៧ បានចុះឈ្មោះដើម្បីធ្វើការប្រកួតប្រជែងនៅក្នុងការបោះឆ្នោតឃុំ/សង្កាត់នៅក្នុងខែមិថុនា ឆ្នាំ២០២២ ។ ក្នុងស្មារតីបង្រួបបង្រួមជាតិ រដ្ឋសភាជាតិបានធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយក្នុងឆ្នាំ២០១៩ ដែលបានបើកផ្លូវដល់ការទទួលបានសិទ្ធិធ្វើនយោបាយឡើងវិញសម្រាប់អ្នកដែលបានបាត់បង់សិទ្ធិនោះដោយសាលក្រមតុលាការ និងសម្រាប់អ្នកដែលកំពុងស្នើសុំសិទ្ធិធ្វើនយោបាយឡើងវិញ។ ជាលទ្ធផល អតីតសមាជិកគណបក្សប្រឆាំងចំនួន៣២រូប បានទទួលសិទ្ធិធ្វើនយោបាយឡើងវិញ។

ឯកឧត្តមរដ្ឋលេខាធិការបានលើកឡើងផងដែរពីកិច្ចសហប្រតិបត្តិការល្អ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះយន្តការអង្គការសហប្រជាជាតិ។ កម្ពុជាបានអនុវត្តសិទ្ធិអធិបតេយ្យរបស់ខ្លួន ដោយឈរលើគោលការណ៍ធម្មនុញ្ញអង្គការសហប្រជាជាតិ។ កម្ពុជាមានមោទនភាពដោយបានប្រែក្លាយពីប្រទេសដែលធ្លាប់ទទួលកងរក្សាសន្តិភាព ទៅជាប្រទេសដែលបញ្ជូនកងរក្សាសន្តិភាពទៅកាន់ប្រទេសមានជម្លោះនៅទូទាំងសកលលោក ក្រោមឆ័ត្ររបស់អង្គការសហប្រជាជាតិ។

លោកសាស្ត្រាចារ្យ **វិទិត មុនតាប៊ិន**ក៏បានអបអរសាទរកម្ពុជាក្នុងនាមជាប្រធានអាស៊ានក្នុងឆ្នាំ២០២២ និងបានទទួលស្គាល់ពីការចូលរួមយ៉ាងសកម្មរបស់កម្ពុជាដល់បុព្វហេតុសន្តិភាពពិភពលោកតាមរយៈការបញ្ជូនកងកម្លាំងកម្ពុជាទៅបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។

ជាចុងបញ្ចប់ លោកសាស្ត្រាចារ្យ **វិទិត មុនតាប៊ិន** បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការជួបសន្ទនាដោយបើកចំហ និងប្រកបដោយការស្តាប់នា ព្រមទាំងកិច្ចសហប្រតិបត្តិការល្អរបស់កម្ពុជាជាមួយអ្នករាយការណ៍ពិសេស។

ថ្ងៃអង្គារ ១២រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២